អាជីវកម្មសាច់ឆ្កែនៅប្រទេសកម្ពុជា ២០១៩

ការរកឃើញសំខាន់ៗនៃការអង្កេតនៅក្នុងខេត្តសៀមរាប

មាតិកា

សេចក្តីសង្ខេប	១
១. ប្រតិបត្តិការនៃអាជីវកម្ម	៤
១.១ ប្រភពសត្វឆ្កែ	៤
១.២ វិធីសាស្ត្រក្នុងការសម្លាប់	៤
១.៣ ការលក់សាច់ឆ្កែ និងបណ្តាញអាជីវកម្ម	៦
១.៤ ផលចំណេញ	៩
២. អតិថិជន	៩
៣. កេរ្តិ៍ឈ្មោះជាអន្តរជាតិ និងវិស័យទេសចរណ៍	៩
៤. ជម្ងឺឆ្កែឆ្លង និងហានិភ័យចំពោះសុខភាពសាធារណៈផ្សេងទៀត	១០
៥. សំណើកិច្ចសហការ និងយុទ្ធដោះស្រាយជាមូលដ្ឋាន	១២
៦. អនុសាសន៍	១៣

សេចក្តីសង្ខេប

អំពីអង្គការ FOUR PAWS

FOUR PAWS គឺជាអង្គការសុខមាលភាពសត្វអន្តរជាតិ ដែលមានទីស្នាក់កណ្តាលនៅទីក្រុង វីយែន (Vienna) ប្រទេសអូទ្រីស (Austria)។ អង្គការនេះត្រូវបានបង្កើតឡើងដោយ លោក Heli Dungler ក្នុងឆ្នាំ១៩៨៨ ដោយមានគោលដៅក្នុងការសង្គ្រោះសត្វដែលត្រូវការជំនួយ តាមរយៈនិរន្តភាពនៃយុទ្ធនាការ និងគម្រោង។ ទស្សនៈវិស័យរបស់ FOUR PAWS គឺពិភពលោកមួយដែលមនុស្សទាំងអស់ប្រព្រឹត្តចំពោះសត្វដោយក្តីគោរព ការយោគយល់ និងការយល់ចិត្ត។ FOUR PAWS គឺជាអង្គការមួយដែលរឹងមាំ ជាសាកល និងមានសម្លេងឯករាជ្យចំពោះសត្វដែលស្ថិតនៅក្រោមការឃុំគ្រងរបស់មនុស្សតាមរយៈ ៖

- បង្កើតដំណោះស្រាយជានិរន្តចំពោះសត្វដែលត្រូវការជំនួយ
- ការរំជួលចិត្ត និងផ្លាស់ប្តូរឥរិយាបថរបស់អ្នកបរិភោគ
- ដឹកនាំការផ្លាស់ប្តូរច្បាប់
- បង្កើតថាមពលនៃភាពជាដៃគូរ

FOUR PAWS ផ្តោតជាចម្បងទៅលើពពួកសត្វដែលស្ថិតនៅក្រោមឥទ្ធិពលរបស់មនុស្សដោយផ្ទាល់ដូចជា សត្វអនាថា សត្វចិញ្ចឹមក្នុងកសិដ្ឋាន សត្វស្រុក និងសត្វព្រៃ ដែលរួមមាន ខ្លាឃ្មុំ អម្បូរសត្វខ្លានិងសត្វតោ និង សត្វអ៊ូរ៉ង់អ៊ូតង់ ដែលត្រូវបានរក្សាទុកនៅក្នុងលក្ខខណ្ឌមិនសមស្រប។

ក្នុងនាមជាអង្គការអន្តរជាតិផ្នែកសុខមាលភាពសត្វ ការងាររបស់ FOUR PAWS មិនត្រូវបានចងភ្ជាប់នៅត្រឹមព្រំដែននៃទីតាំងភូមិសាស្ត្រនោះទេ។ អង្គការ FOUR PAWS មានការិយាល័យនៅបណ្តាប្រទេសមួយចំនួន ដូចជា អូស្ត្រាលី អូទ្រីស បែលហ្ស៊ិក ប៊ុលហ្គារី អាល្លឺម៉ង់ ហុងគ្រី កូសូវ៉ូ ហូឡង់ អាហ្វ្រិកខាងត្បូង ស្វីស ថៃ អ៊ុយក្រែន អង់គ្លេស សហរដ្ឋអាមេរិច និងវៀតណាម។ គម្រោងជំនួយថ្នាក់ជាតិ និងអន្តរជាតិ ផ្តល់ជំនួយយ៉ាងរហ័ស និងដោយផ្ទាល់ដល់សត្វទាំងឡាយដែលត្រូវការជំនួយ និងពពួកសត្វព្រៃទាំងឡាយដែលត្រូវបានគេថែរក្សាទុកក្នុងស្ថានភាពគ្រោះថ្នាក់ ដើម្បីទទួលបានជម្រកថ្មីសមស្របទៅតាមប្រភេទសត្វនីមួយៗ។ ការងាររបស់ FOUR PAWS គឺផ្អែកលើការស្រាវជ្រាវដោយមានភស្តុតាង និងមានជំនាញផ្នែកវិទ្យាសាស្ត្រ ហើយរួមទាំងការងារបញ្ចុះបញ្ចូលថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ គោលដៅរបស់យុទ្ធនាការ គម្រោងផ្សេងៗ និងការងារអប់រំ គឺដើម្បីផ្តល់ព័ត៌មានដល់សាធារណៈជន អំពីការឈឺចាប់រងគ្រោះរបស់សត្វ និងឈានទៅដល់ការកែលម្អរយៈពេលវែងតាមរយៈការចែងនៅក្នុងច្បាប់។

អំពីអង្គការសង្គ្រោះសត្វកម្ពុជា៖

អង្គការសង្គ្រោះសត្វកម្ពុជា គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញមួយ ដែលបានបង្កើតឡើងក្នុងឆ្នាំ ២០១៦ ក្នុងគោលបំណងបង្កើតបាននូវសុខមាលភាពសត្វ ដែលប្រកបដោយនិរន្តភាពនៅក្នុងប្រទេសកម្ពុជា។ ដោយមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ អង្គការមួយនេះមានការប្តេជ្ញាចិត្តក្នុងការបង្កើតបាននូវការផ្លាស់ប្តូរមួយ ដែលមានភាពយូរអង្វែង និងប្រកបដោយនិរន្តភាពនៃស្ថេរភាពសុខមាលភាពសត្វ នៅក្នុងប្រទេសកម្ពុជា តាមរយៈ សកម្មភាពខាងក្រោម៖

1. ការគ្រប់គ្រងចំនួនសត្វ តាមវិធីសាស្ត្រប្រកបដោយមនុស្សធម៌ ក៏ដូចជាការលើកកម្ពស់សុខភាពសត្វ និងការចាំទាំ និងការផ្តល់នូវជម្រកដល់សត្វ
2. ការលើកទឹកចិត្ត និងបំផុសគំនិតអាយមានការផ្លាស់ប្តូរនអ្នកប្រកិរិយារបស់ប្រជាជនកម្ពុជាទាក់ទងទៅនឹងផ្តន ត់គំនិត ដែលពួកគាត់មានទៅលើសត្ និងការឆ្លើយតបបន្ទាន់ទៅនឹងហេតុការណ៍ផ្សងៗ
3. ការផ្តើអាយមានភាពប្រសើរឡើងនវិស័យវជ្រេជសាស្ត្រសត្វ
4. ការគាំទ្រក្នុងការដាក់អនុវត្តនច្បាប់សុខុមាលភាពសត្វ

ការផ្លាស់ប្តូរអាកប្បកិរិយា និងផ្តន ត់គំនិតដែលប្រជាជនកម្ពុជាមានទៅលើសត្វគឺជាគន្លឹះនផែនែការរបស់អង្គការសង្គ្រោះសត្វកម្ពុជា ពីព្រោះ នេះគឺជាផ្លូវមួយគត់ ដែលអាចធ្វើឱ្យអនាគតរបស់សត្វអនាថានៅប្រទេសកម្ពុជា មានភាពប្រសើរឡើង។ គម្រោងក្នុងសុរុកផ្សងៗមានដូចជា៖ កម្មវិធី HQHVSN សម្រាប់សត្វសុនខ និងពិឡារនៅក្នុងគ្លួសារក្តីក្រ ក៏ដូចជាការឃ្លាំមើលទៅលើបញ្ហាជំងឺឆ្កឆ្កែកួត និងកម្មវិធីអប់រំផ្សងៗ ។ល។

វបេសាយ៖ https://ar-cambodia.com | ហ្វសេប៊ុក៖ www.facebook.com/animalrescuecambodia

ការរៀបចំស្ថាប័ន

នៅក្នុងប្រទេសកម្ពុជា អង្គការ FOUR PAWS និងអង្គការ Animal Rescue Cambodia បានចុះអនុស្សារណៈយោគយល់ជាមួយ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) ដើម្បីប្រយុទ្ធប្រឆាំងនឹងអាជីវកម្មសាច់ឆ្កែនៅក្នុងប្រទេសកម្ពុជា នាខែធ្នូ ឆ្នាំ២០១៨។ នៅក្នុងខែកក្កដា ឆ្នាំ២០១៩ អង្គការ FOUR PAWS អង្គការ ARC និងអង្គភាព CMAC បានរៀបចំសិក្ខាសាលាស្តីពី "វិរៈភាពសុនខ" នៅរាជធានីភ្នំពេញ ដើម្បីអបអរតួនាទីសំខាន់របស់សត្វឆ្កែនៅក្នុងសង្គមខ្មែរ និងផលវិបាកដែលអាចបង្កឡើងដោយការបរិភោគសាច់ឆ្កែ។

ការដោះស្រាយអាជីវកម្មសាច់ឆ្កែ

អង្គការ FOUR PAWS និងអង្គការ ARC មានការប្តេជ្ញាចិត្ត ក្នុងការធ្វើកិច្ចការងារដោយសហការជាមួយអាជ្ញាធរខេត្តសៀមរាប ដើម្បីដោះស្រាយអាជីវកម្មសត្វឆ្កែ និងលើកសំណើរផែនការសកម្មភាពរួមគ្នាដែលពាក់ព័ន្ធទៅនឹងសកម្មភាពផ្សព្វផ្សាយសាធារណៈរួមមួយ ដោយភ្ជាប់ជាមួយសកម្មភាពក្នុងការបិទទីតាំងសត្តឃាត ភោជនីយដ្ឋាន និងការបញ្ចប់អាជីវកម្មសាច់ឆ្កែ តាមរយៈការផ្តល់ការគាំទ្រ និងជំនួយនៅនឹងកន្លែង។ អង្គការទាំងពីរក៏បានត្រៀមរួចជាស្រេចដើម្បីជួយដល់រាជរដ្ឋាភិបាលក្នុងការធ្វើយុទ្ធនាការប្រកបដោយប្រសិទ្ធភាព និងភាពជាវិជ្ជមាននៅតាមបណ្តាទីក្រុង ដើម្បីដោះស្រាយសកម្មភាពផ្សេងៗដែលពាក់ព័ន្ធជាមួយអាជីវកម្មសាច់ឆ្កែ និងប្រារព្ធកម្មវិធីអបអរសត្វឆ្កែជាសត្វចិញ្ចឹម មិនមែនសម្រាប់ធ្វើជាអាហារ។ ផ្អែកលើបទពិសោធន៍ការងារជាច្រើនឆ្នាំពាក់ព័ន្ធនឹងបញ្ហានេះនៅតាមបណ្តាប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍ យើងអាចផ្តល់ជូនអ្នកជំនាញដល់អាជ្ញាធរផ្តល់ការគាំទ្រ និងធនធានដែលចាំបាច់ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញនិងផលវិបាកផ្លូវចិត្ត។

ការរកឃើញនៅក្នុងការអង្កេតកម្រិតខ្ពស់

តាមការវាយតម្លៃសត្វឆ្កែប្រមាណ ២.៩០០ក្បាល (៣៤.០០០ក្បាល ក្នុងមួយឆ្នាំ ត្រូវបានគេ ផ្គត់ផ្គង់ទៅកាន់បណ្តា ភោជនីយដ្ឋាន ក្នុងក្រុង សៀមរាប

ចាប់តាំងពីខែធ្នូ ឆ្នាំ២០១៨ ដល់ខែឧសភា ឆ្នាំ២០១៩ អង្គការ FOUR PAWS និង អង្គការ ARC បានធ្វើការអង្កេតស៊ីជម្រៅពាក់ព័ន្ធទៅនឹងអាជីវកម្មសាច់ឆ្កែនៅក្នុងប្រទេសកម្ពុជា ដោយផ្តោតទៅលើតំបន់ដែលជាប្រភពនៃសត្វឆ្កែ ទីតាំងសត្តឃាត និងកន្លែងលក់។ ខេត្តសៀមរាប ត្រូវបានកំណត់ថាជាចំណុចក្តៅនៃប្រភពសត្វឆ្កែ ជាកន្លែងផ្គត់ផ្គង់តម្រូវការសាច់ឆ្កែនៅពាក់កណ្តាលភាគខាងកើតនៃប្រទេសកម្ពុជា ជាពិសេសរាជធានីភ្នំពេញ។ តាមរយៈការអង្កេតបានបង្ហាញថា អាជីវកម្មសាច់ឆ្កែនៅក្នុងខេត្តសៀមរាបមានទំហំធំគួរឱ្យកត់សម្គាល់ គឺចំនួនសត្វឆ្កែច្រើនជាង ៧.០០០ក្បាល ក្នុងមួយខែ។ ក្នុងកំឡុងពេលនៃការអង្កេត គឺមានភោជនីយដ្ឋានលក់សាច់ឆ្កែចំនួន ២១ទីតាំង ដែលកំពុងមានសកម្មភាពនៅក្នុង និងជុំវិញខេត្តសៀមរាប ដោយជាមធ្យមលក់ឆ្កែពី ០៤-០៦ក្បាល ក្នុងមួយថ្ងៃអាស្រ័យលើរដូវកាល។ យោងតាមការប៉ាន់ស្មាន សត្វឆ្កែចំនួន ២.៩០០ក្បាល ក្នុងមួយខែ (៣៤.៨០០ក្បាល ក្នុងមួយឆ្នាំ) ត្រូវបានលក់នៅតាមបណ្តាភោជនីយដ្ឋាននៅក្នុងក្រុងសៀមរាប។ តាមរយៈការអង្កេត យើងក៏បានកំណត់ទីតាំងសត្តឃាតចំនួន ០១កន្លែង និងទីតាំងស្តុកនិងជួញដូរសត្វឆ្កែចំនួន ០៥កន្លែង នៅខាងក្រៅទីក្រុង ដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាទុកសត្វឆ្កែមុនពេលដឹកជញ្ជូនទៅកាន់ទីសត្តឃាត។ រថយន្ត MiniVans ដែលមានដាក់ទ្រុងសត្វឆ្កែ ត្រូវបានប្រើប្រាស់ដើម្បីដឹកជញ្ជូនសត្វឆ្កែចេញពីខេត្តសៀមរាប គឺប្រហែល ៣.៧៥០ក្បាល ក្នុងមួយខែ និងសត្វឆ្កែពីតំបន់ផ្សេងៗទៀតនៅក្នុងប្រទេសដើម្បីផ្គត់ផ្គង់សាច់ឆ្កែនៅតាមបណ្តាភោជនីយដ្ឋានក្នុងរាជធានីភ្នំពេញ តាមរយៈទីសត្តឃាតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ស្រុកបាធាយ និងស្រុកជើងព្រៃ (ស្ពន់ ខេត្តកំពង់ចាម និងស្រុកមុខកំពូល ខេត្តកណ្តាល។

ទីសត្តឃាត កន្លែងស្មុក និងភោជនីយដ្ឋានលក់សាច់ឆ្កែ បានជម្រុញឱ្យមានអំពើចោរកម្ម និងការដោះដូរសត្វឆ្កែនៅតាមបណ្តាខេត្តជុំវិញ ដែលបានបង្ហាញឱ្យឃើញថាសត្វឆ្កែមួយចំនួនត្រូវបានគេលួចទាក់មក។ មុខជំនួញដ៏ធំ និងគ្មានច្បាប់ទម្លាប់នេះ បានបង្កឱ្យមានការទាក់ឆ្កែ និងចលនាបម្លាស់ទីដ៏ធំសម្បើមនៃសត្វឆ្កែដែលមានជម្ងឺហើយមិនអាចកំណត់បាននិងមិនបានចាក់វ៉ាក់សាំងបង្ការ ទៅកាន់បណ្តាទីក្រុងផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ បញ្ហាទាំងនេះបានបង្កឱ្យមានការព្រួយបារម្ភជាខ្លាំងអំពីកម្រិតឆ្លងកាន់តែខ្ពស់នៃជម្ងឺឆ្កែឆ្លងនៅក្នុងប្រទេសកម្ពុជា ហើយសត្វឆ្កែដែលមានផ្ទុកជម្ងឺឆ្កែឆ្លង ត្រូវបានដាក់ចូលទៅក្នុងអាជីវកម្មដើម្បីធ្វើជាអាហារបម្រើដល់សេចក្តីត្រូវការរបស់មនុស្ស។ ការទាក់ឆ្កែ និងការសម្លាប់ឆ្កែ និងការបរិភោគសត្វឆ្កែ ធ្វើឱ្យមានភាពអន្តរាយដល់សុខភាព និងសុវត្ថិភាព នៅទូទាំងប្រទេស និងបង្កឱ្យមានផលវិបាកយ៉ាងខ្លាំងដល់សង្គម សេដ្ឋកិច្ច និងសុខមាលភាពសត្វ។ អាជីវកម្មសាច់ឆ្កែក៏បានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់កេរ្តិ៍ឈ្មោះជាអន្តរជាតិ ដែលជាគោលដៅទេសចរណ៍ដ៏សំខាន់ ជាពិសេសវត្តមានដ៏ច្រើននៃភោជនីយដ្ឋានដែលលក់សាច់ឆ្កែនៅតំបន់អង្គវត្ត។

ការអង្កេតរបស់យើងបានចងក្រងជាឯកសារ និងផ្តិតយករូបភាពនៃការប្រមូល ការដឹកជញ្ជូន និងវិធីសាស្ត្រឃោរឃៅក្នុងការសម្លាប់សត្វឆ្កែ រួមទាំងកិច្ចសម្ភាសន៍យ៉ាងលម្អិតជាមួយអ្នកពាក់ព័ន្ធ។ ក្រៅពីការអង្កេត ការសិក្សាស្រាវជ្រាវទីផ្សារក៏ត្រូវបានយកមកអនុវត្តដើម្បីវាយតម្លៃអត្រាប្រែប្រួលនៃការបរិភោគសាច់ឆ្កែ និងឥរិយាបថរបស់មនុស្ស។ ការសិក្សាបានបង្ហាញថាប្រជាជនកម្ពុជាភាគច្រើនយល់ឃើញថាការបរិភោគសាច់ឆ្កែ គឺជាអំពើបាប ហើយវាមិនមែនជាវប្បធម៌ និងប្រពៃណីខ្មែរនោះទេ។

ហានិភ័យសុខភាពសាធារណៈ និងភាពខុសច្បាប់

ទីតាំងសត្តឃាតនៅក្នុងខេត្តសៀមរាប មិនបានបំពេញតាមស្តង់ដារអនាម័យជាមូលដ្ឋាន និងមិនបានចុះបញ្ជីត្រឹមត្រូវ។ ការដឹកជញ្ជូន ការសម្លាប់សត្វឆ្កែ ការលក់សាច់ឆ្កែ ក៏បានធ្វើឡើងផ្ទុយអំពីច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ និងផ្ទុយទៅនឹងអនុក្រឹត្យលេខ ១០៨ អនក្រ.បក ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសាច់ សត្វ និងផលិតផលសត្វ។

ការដឹកជញ្ជូន ការសម្លាប់ ការលក់សាច់ឆ្កែ គឺបានបំពានច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

អាជីវកម្មសាច់ឆ្កែបានបង្កឱ្យមានហានិភ័យចំពោះសុខភាពសាធារណៈគួរឱ្យកត់សម្គាល់ជាពិសេសជម្ងឺឆ្កែឆ្លង។ ក៏ដូចជាបណ្តាប្រទេសដទៃទៀតនៅក្នុងក្រុម **អាស៊ាន + បី** គឺប្រទេសកម្ពុជាមានគោលដៅលុបបំបាត់ជម្ងឺឆ្កែឆ្លងត្រឹមឆ្នាំ ២០៣០ ប៉ុន្តែវាប្រឈមទៅនឹងឧបសគ្គមួយចំនួន។ នាពេលបច្ចុប្បន្នប្រទេសកម្ពុជា មិនទាន់មានកម្មវិធីចាក់វ៉ាក់សាំងជម្ងឺឆ្កែឆ្លងផ្លូវការនោះទេ មិនទាន់មានយុទ្ធសាស្ត្រដាក់ចេញជាក់លាក់ មានអាជីវកម្មសាច់ឆ្កែដែលមិនសូវមានការស្វាគមន៍ និងកង្វះខាតមូលនិធិដើម្បីលុបបំបាត់ជម្ងឺឆ្កែឆ្លងនៅប្រទេសកម្ពុជា។ អាជីវកម្មសាច់ឆ្កែបានបង្កជាហានិភ័យក្នុងការឆ្លងជម្ងឺឆ្កែឆ្លងដល់អ្នកទាក់ឆ្កែ អ្នកសម្លាប់ឆ្កែ អ្នកបរិភោគសាច់ឆ្កែ និងភ្ញៀវទេសចរណ៍បរទេស ការលុបបំបាត់អាជីវកម្មសាច់ឆ្កែ រួមជាមួយកម្មវិធីចាក់វ៉ាក់សាំងសត្វឆ្កែ គឺជាមធ្យោបាយតែមួយគត់ក្នុងការចំណាយប្រកបដោយប្រសិទ្ធភាពជាងគេដើម្បីកាត់បន្ថយករណីមនុស្សកើតជម្ងឺឆ្កែឆ្លង។

កាលានុវត្តភាពនៃកិច្ចសហការ

នៅក្នុងខែតុលា អង្គការ FOUR PAWS នឹងចាប់ផ្តើមយុទ្ធនាការជាអន្តរជាតិដើម្បីដោះស្រាយអាជីវកម្មសាច់ឆ្កែខុសច្បាប់ ដោយយោងទៅលើការប្រព្រឹត្តសាហាវឃោរឃៅចំពោះសត្វ ហានិភ័យដែលអាចប៉ះពាល់ដល់សុវត្ថិភាព សុខភាពសាធារណៈ តាមរយៈការចម្លងជម្ងឺឆ្កែឆ្កួត និងផលប៉ះពាល់ជាអវិជ្ជមានក្នុងវិស័យទេសចរណ៍។ ក្នុងកិច្ចសហការជាមួយអាជ្ញាធរខេត្តសៀមរាប អង្គការ FOUR PAWS និងអង្គការ ARC មានគោលបំណងធ្វើឱ្យបានសម្រេចបាននូវគោលដៅចំនួនពីរ គឺលុបបំបាត់អាជីវកម្មសាច់ឆ្កែ និងការពារសុខភាពសាធារណៈ។

១. ប្រតិបត្តិការនៃអាជីវកម្ម

១.១ ប្រភពសត្វ

ប្រភពភាគច្រើននៃការផ្គត់ផ្គង់សត្វឆ្កែសម្រាប់អាជីវកម្មសាច់ឆ្កែ គឺសត្វឆ្កែអនាថា និងសត្វឆ្កែដែលមានម្ចាស់ ដែលត្រូវបានប្រមូលទិញ និងទាក់យកដោយក្រុមអ្នកប្រកបរបរនេះ។ ដំណើរការនៃប្រមូលសត្វឆ្កែ គឺមានភាពឃោរឃៅ សត្វឆ្កែភាគច្រើនត្រូវគេវាយទៅលើក្បាលដោយបង្ខំ។ ជាទូទៅសត្វឆ្កែទទួលរងការបាក់ឆ្អឹង រងរបួស និងបញ្ហាផ្សេងៗទៀតនៅពេលគេចាប់។ សត្វឆ្កែមួយចំនួនបានស្លាប់ មុនពេលគេយកទៅសម្លាប់នៅទីសត្តឃាតដោយសាររបួសដែលកើតឡើងក្នុងពេលចាប់។ នៅទីសត្តឃាតមួយកន្លែងក្នុងខេត្តកណ្តាល យើងបាន សង្កេតឃើញសត្វឆ្កែ ០១ក្បាល ដែលឆ្អឹងថ្ពាមក្រោមរបស់វាត្រូវបានបាក់ទាំងស្រុង។

សត្វឆ្កែ ០១ក្បាល នេះត្រូវបានដឹកយកមកកាលពី ០១ថ្ងៃមុន ពីខេត្តសៀមរាប។ ជារឿយៗ ក្រុមអ្នកដោះដូរសត្វឆ្កែជាមួយឆ្នាំង ខ្នះ ឬកូនឆ្កែជាមួយឆ្កែជំទង់ តែងធ្វើដំណើរទៅកាន់តំបន់ក្រក្រី និងតំបន់ដាច់ដាច់ស្រយាល។ សត្វឆ្កែមួយចំនួនត្រូវបានគេទាក់យក ជាពិសេសពីវត្តអារាម។

សត្វឆ្កែភាគច្រើនដែលត្រូវបានគេសម្លាប់ ឬធ្វើអាជីវកម្មក្នុងខេត្តសៀមរាប មានប្រភពមកពីតំបន់ក្បែរព្រំដែនកម្ពុជា-ថៃ។ គឺមានបណ្តាញអាជីវកម្មដ៏ធំនៅតាមតំបន់ក្បែរព្រំដែន ហើយអ្នកធ្វើអាជីវកម្មជាច្រើនបានធ្វើដំណើររាប់រយគីឡូម៉ែត្រខាងក្រៅខេត្តសៀមរាប ដើម្បីប្រមូលសត្វឆ្កែ។ ក្រុងប៉ោយប៉ែត ត្រូវបានគេចាត់ទុកថាជាទីក្រុងដ៏ពេញនិយមសម្រាប់ការជួញដូរសត្វឆ្កែខុសច្បាប់ពីប្រទេសថៃ។

១.២ វិធីសាស្ត្រក្នុងការសម្លាប់

នៅក្នុងកំឡុងពេលអង្កេត យើងបានសង្កេតឃើញ ពីវិធីសាស្ត្រផ្សេងៗជាច្រើនត្រូវបានយកមកប្រើដើម្បីសម្លាប់សត្វឆ្កែ។ វិធីសាស្ត្រទាំងអស់នោះគឺមានភាពឃោរឃៅ អមនុស្សធម៌ និងបង្កឱ្យមានការឈឺចាប់រយៈពេលវែង។ នៅគ្រប់ទីកន្លែងសត្តឃាតគឺមិនមានអនាម័យនោះទេ ហើយរាល់សត្វឆ្កែដែលត្រូវបានគេសម្លាប់គឺស្ថិតនៅក្រោមក្រសែភ្នែករបស់សត្វឆ្កែដទៃទៀត។ វិធីសាស្ត្រជាទូទៅដែលប្រើដើម្បីសម្លាប់សត្វឆ្កែ រួមមាន ៖

- វាយទៅលើក្បាល ០៣ ឬ ០៤ដង រួចយកកាំបិតចាក់ក។ បន្ទាប់មកយកសត្វឆ្កែទៅព្យួរជើងឡើង ទៅលើ ឬទុកចោលនៅហ្នឹងកន្លែងរហូតដល់ហូរឈាមអស់។ វិធីសាស្ត្រនេះបានបង្កឱ្យមាន ការឈឺចាប់យូរមុនពេលស្លាប់។ វិធីនេះត្រូវចំណាយពេល ១៥នាទី ចាប់តាំងពីការវាយក្បាលឆ្កែ រហូតដល់ឆ្កែស្លាប់។
- វិធីសាស្ត្រជ្រមុជទឹក គឺជាវិធីសាស្ត្រដែលពេញនិយមក្នុងការសម្លាប់សត្វឆ្កែ ០៣ ឬ ០៤ក្បាល ក្នុងពេលតែមួយ។ សត្វឆ្កែត្រូវបានគេដាក់ចូលទៅក្នុងទ្រុងដែកតូចមួយ រួចដាក់ចូលទៅក្នុងរណ្តៅទឹកកខ្វក់មួយ។ វិធីសាស្ត្រនេះគឺ

ស្លាប់យឺត និងឈឺចាប់។

- វិធីសំលាប់ដោយការចងរឹតកន្ដែនីមួយៗនៅក្នុងទ្រុងដោយប្រើខ្សែ ការសម្លាប់ដោយវិធីនេះធ្វើឱ្យឆ្កែបាក់ធ្មេញដោយសារការខាំរបារដែកទ្រុង ឬខាំដំបង ដើម្បីព្យាយាមរំដោះខ្លួនចេញ។ វិធីសម្លាប់មួយទៀតគឺ សត្វឆ្កែត្រូវបានគេចងព្យួរកលើដើមឈើរយៈពេលរហូតដល់ ៣០នាទី រហូតដល់វាចប់ដង្ហើមស្លាប់។
- សត្វឆ្កែដែលត្រូវបានដឹកជញ្ជូនពី ខេត្តសៀមរាប និងខេត្តកណ្តាល ដើម្បីផ្គត់ផ្គង់នៅតាមភោជនីយដ្ឋានក្នុងរាជធានីភ្នំពេញ ភាគច្រើនត្រូវបានសម្លាប់ដោយវិធីសាស្ត្រជ្រមុជទឹក។

នៅកំឡុងពេលអង្កេត យើងបានសង្កេតឃើញថា មានវិធីសាស្ត្រផ្សេងៗជាច្រើនត្រូវបានយកមកប្រើដើម្បីសម្លាប់សត្វឆ្កែ



ជាអកុសល សត្វឆ្កែភាគច្រើនគឺនៅរស់ឡើយក្នុងកំឡុងពេលអនុវត្តជំហាននេះ ដើម្បីសម្លាប់សត្វឆ្កែ

នៅក្នុងជំហានបន្ទាប់ គឺសត្វឆ្កែត្រូវបានយកទៅដាក់នៅក្នុងទឹកក្តៅដើម្បីកោសរោមរបស់វាដោយប្រើកាំបិត។ ជាអកុសល សត្វឆ្កែភាគច្រើនគឺនៅរស់ឡើយក្នុងកំឡុងពេលអនុវត្តជំហាននេះ។

១.៣ ការលក់សាច់ឆ្កែ និងបណ្តាញអាជីវកម្ម

ភោជនីយដ្ឋាន



នៅពេលធ្វើការអង្កេត យើងបានឃើញភោជនីយដ្ឋានដែលសកម្មក្នុងការលក់សាច់ឆ្កែចំនួន ២១ទីតាំង នៅក្នុងក្រុងសៀមរាប។ ភោជនីយដ្ឋានទាំងអស់នោះ គឺអាចមើលឃើញយ៉ាងច្បាស់ដោយមានសញ្ញាសម្គាល់ថាលក់សាច់ឆ្កែ ឬតាមរយៈការចង្អុលបង្ហាញពីអ្នកភូមិ។ យើងពិតជាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលភោជនីយដ្ឋានមួយចំនួនស្ថិតនៅក្បែរប្រាសាទអង្គរវត្ត។ មានភោជនីដ្ឋានមួយ មានទីតាំងស្ថិតនៅខាងក្រៅច្រកចូលខាងលិច (ក្បែរប្រាសាទតាព្រហ្មកិល មានចម្ងាយ ៥៧០ម៉ែត្រ ពីច្រកចូលប្រាសាទអង្គរវត្ត។ មានភោជនីយដ្ឋានចំនួន ០៨ទីតាំង ត្រូវបានកត់ត្រាថាស្ថិតនៅក្នុងរង្វង់អ័ក្ស ០៥គីឡូម៉ែត្រពីប្រាសាទអង្គរវត្ត។

ភោជនីយដ្ឋានភាគច្រើនទទួលបានការផ្គត់ផ្គង់សាច់ឆ្កែពីអ្នកផ្គត់ផ្គង់នៅ ភូមិព្រះដាក់ ត្រាំនាគ និងខ្នារថ្មី។ ជាមធ្យមភោជនីយដ្ឋាននីមួយៗ លក់សាច់ឆ្កែ ពី ០៤-០៦ក្បាលក្នុងមួយថ្ងៃ អាស្រ័យទៅតាមរដូវកាល។ ភោជនីយដ្ឋានទាំងនោះភាគច្រើនទទួលយកសាច់ឆ្កែដែលធ្វើរួចជាស្រេចពីអ្នកផ្គត់ផ្គង់ មានតែភោជនីយដ្ឋាន ០២ ឬ ០៣ទីតាំងប៉ុណ្ណោះទទួលយកឆ្កែរស់មកធ្វើខ្លួនឯង។ ម្ចាស់ភោជនីយដ្ឋានដែលទទួលយកឆ្កែមកសម្លាប់ដោយខ្លួនឯង ដោយមិនទទួលសាច់ឆ្កែដែលធ្វើរួចពីអ្នកផ្គត់ផ្គង់ មានការកើនឡើងនូវប្រាក់ចំណេញ។

នៅតាមភោជនីយដ្ឋានលក់សាច់ឆ្កែ សាច់អាំងគឺជាមុខម្ហូបដែលពេញនិយមបំផុត បន្ទាប់មកទៀតគឺសម្លរម្ហូរ និងការី។ ចំណែកឯសរីរាង្គខាងក្នុង រួមទាំងក្រពះ ពោះវៀនដែលបានញាត់បាយ និងជីរខាងក្នុង ក៏ត្រូវបានគេទទួលទានផងដែរ។ កន្ទុយរបស់ឆ្កែក៏ត្រូវបានចាត់ទុកថាជាកន្លែងដែលឆ្ងាញ់ សម្រាប់យកមកអាំង។ ក្បាលឆ្កែទាំងមូលដែលមានខួរនៅខាងក្នុងក៏ត្រូវបានយកមកអាំងលក់ផងដែរ។

ទីសត្តឃាត

នៅក្នុងខេត្តសៀមរាប មានទីសត្តឃាតទាំងធំ ទាំងតូចមួយចំនួន ជាកន្លែងសម្រាប់ទទួលសម្លាប់សត្វឆ្កែ និងផ្គត់ផ្គង់សាច់ឆ្កែដល់បណ្តាភោជនីយដ្ឋានក្នុងខេត្ត។ ក្រៅពីទីសត្តឃាតខាងលើ នៅមានកន្លែងមួយចំនួនទៀតដែលទទួលសម្លាប់សត្វឆ្កែតែក្នុងបរិមាណតិចតួច ហើយភាគច្រើនប្រើប្រាស់វិធីសាស្ត្រពុួរក។ ទីកន្លែងសត្តឃាតទាំងនោះមានទីតាំងស្ថិតនៅ ភូមិព្រះដាក់ ភូមិត្រាំនាគ និងភូមិខ្នាថ្មី។ ក្រៅពីទទួលសម្លាប់សត្វឆ្កែក្នុងបរិមាណតិចតួច អ្នកភូមិក៏ទទួលផ្គត់ផ្គង់ឆ្កែរស់ទៅកាន់រាជធានីភ្នំពេញ ដោយឆ្លងកាត់តាមខេត្តកំពង់ចាម និងកណ្តាល។ ភោជនីយដ្ឋានមួយចំនួននៅក្នុងខេត្តសៀមរាប ត្រូវបានរាយការណ៍ថាមានករណីប្តឹងតវ៉ាបញ្ហាសម្លេងរំខានពីអ្នកជិតខាង ដែលភោជនីយដ្ឋានទាំងនោះទិញឆ្កែរស់ពីសត្តឃាតក្រៅក្រុង។

ទីតាំងស្តុក និងផ្លូវដឹកជញ្ជូន

អ្នកជួញដូរបានប្រើប្រាស់ម៉ូតូដែលមានភ្ជាប់ទ្រុងពីក្រោយក្នុងការដឹកជញ្ជូនសត្វឆ្កែនៅជុំវិញខេត្ត។ ពួកគេធ្វើដំណើររាប់រយគីឡូម៉ែត្រដើម្បីប្រមូលយកសត្វឆ្កែជារៀងរាល់ថ្ងៃ រួចបញ្ជូនទៅកាន់កន្លែងស្តុក។ សត្វឆ្កែភាគច្រើនត្រូវចំណាយពេលជាច្រើនម៉ោងនៅក្នុងទ្រុងដ៏ចង្អៀតជាមួយសត្វឆ្កែដទៃរហូតដល់ទ្រុងរបស់ពួកគេពេញ។

អាជីវកម្មសាច់ឆ្កែនៅក្នុងខេត្តសៀមរាប និងតំបន់ជុំវិញ គឺជាមុខរបរពេញនិយមក្នុងការរកប្រាក់កម្រៃ។ នៅក្នុងភូមិព្រះដាក់ ភូមិត្រាំនាគ និងភូមិខ្នាថ្មី អ្នកភូមិភាគច្រើនមានជាប់ពាក់ព័ន្ធទៅនឹងអាជីវកម្មសាច់ឆ្កែ។ ភូមិព្រះដាក់ ភូមិត្រាំនាគ គឺជាទីតាំងស្តុក

ទុកនិងជួញដូរដ៏ធំមួយ ដែលក្នុងនោះអ្នកជួញដូរម្នាក់បានរាយការណ៍ពីប្រាក់ចំណេញហូតដល់ ១.៥០០ដុល្លារ ក្នុងមួយខែ។ នៅទីនោះសត្វឆ្កែដែលត្រូវបានគេជួញដូរចំនួនរាប់រយក្បាល ត្រូវបានដឹកជញ្ជូនឆ្លងកាត់ជារៀងរាល់សប្តាហ៍ ហើយអ្នកភូមិចំនួន ១០-១៥គ្រួសារ មានជាប់ពាក់ព័ន្ធទៅនឹងអាជីវកម្មនេះ។ កូនឆ្កែតូចៗអាយុត្រឹម ៣ខែ ត្រូវបានរក្សាទុកនៅក្នុងទ្រុង រង់ចាំការដឹកជញ្ជូនទៅកាន់ទីសត្តឃាត។ នៅក្នុងទីតាំងស្តុក សត្វឆ្កែត្រូវឃុំទុកនៅក្នុងទ្រុងដែក និងរក្សាទុកជាច្រើនថ្ងៃដោយគ្មានអាហារនិងទឹកគ្រប់គ្រាន់។ សត្វឆ្កែភាគច្រើនបង្ហាញអាការៈភ័យខ្លាច ញាប់ញ័រនៅក្នុងទ្រុង។

ក្រុមអ្នកដឹកជញ្ជូនបានប្រើប្រាស់រថយន្ត MiniVans ដែលមានបំពាក់ទ្រុងសត្វឆ្កែនៅក្នុង ដើម្បីដឹកជញ្ជូនសត្វឆ្កែរស់ចំនួនរាប់រយក្បាលពីទីតាំងស្តុកក្នុងខេត្តសៀមរាប ទៅកាន់ទីសត្តឃាតនៅក្នុងខេត្តកំពង់ចាម និងខេត្តកណ្តាល។ តាមរយៈការអង្កេតបានរកឃើញថា រថយន្ត MiniVans ផ្ទុកឆ្កែរស់ជាច្រើនរយក្បាល ត្រូវបានដឹកពីខេត្តសៀមរាប មកកាន់ទីសត្តឃាត ខេត្តកណ្តាល និងខេត្តកំពង់ចាម ជារៀងរាល់ថ្ងៃ។ តាមការប៉ាន់ស្មានសត្វឆ្កែរស់ប្រមាណ ៣.៧៥០ក្បាល ត្រូវបានដឹកចេញពីខេត្តសៀមរាប ជារៀងរាល់ខែទៅកាន់ទីសត្តឃាតដើម្បីផ្គត់ផ្គង់អាជីវកម្មសាច់ឆ្កែនៅក្នុងរាជធានីភ្នំពេញ។ ក្រុមការងារអង្កេតរបស់ អង្គការ FOUR PAWS បានទៅមើលភោជនីយដ្ឋានលក់សាច់ឆ្កែចំនួន ១១០ទីតាំង នៅក្នុងរាជធានីភ្នំពេញ។ ប្រសិនបើ ភោជនីយដ្ឋាននីមួយៗសម្លាប់ឆ្កែចំនួន ០៤-០៦ក្បាល ក្នុងមួយថ្ងៃ នោះក្នុងមួយឆ្នាំមានតម្រូវការឆ្កែជាង ២០០.០០០ក្បាល សម្រាប់ផ្គត់ផ្គង់ភោជនីយដ្ឋានទាំងអស់នៅក្នុងក្រុង។ សាច់ឆ្កែភាគច្រើនដែលបានដាក់លក់នៅតាមភោជនីយដ្ឋានមានប្រភពមកពីខេត្តសៀមរាប។ សត្វឆ្កែប្រមាណ ២-៣លានក្បាល ក្នុងមួយឆ្នាំ ត្រូវបានសម្លាប់ដើម្បីបម្រើដល់អាជីវកម្មសាច់ឆ្កែនៅក្នុងប្រទេសកម្ពុជា។

គោលដៅចុងក្រោយ

សត្វឆ្កែទាំងអស់ដែលត្រូវបានដឹកជញ្ជូនចេញពីខេត្តសៀមរាប ហើយនឹងត្រូវទទួលរងនូវភាពឃោរឃៅនៅតាមទីសត្តឃាតនានានៅក្នុងខេត្តកណ្តាល និងខេត្តកំពង់ចាម។ សត្វឆ្កែត្រូវបានជ្រមុជទៅក្នុងទឹករហូតដល់ស្លាប់ ហើយកោសរោមចេញ និងលក់ទៅកាន់ភោជនីយដ្ឋាននៅក្នុងរាជធានីភ្នំពេញ។ ទីសត្តឃាត ០១ នៅក្នុងខេត្តកណ្តាល បានឱ្យដឹងពីចំនួនសត្វឆ្កែដែលបានសម្លាប់ពី ៦០-១០០ក្បាល ក្នុងមួយថ្ងៃ។ នៅក្នុងខេត្តកណ្តាល មានទីសត្តឃាតចំនួន ០៣ទីតាំង ដែលជាកន្លែងទទួលសត្វឆ្កែក្នុងបរិមាណច្រើន និងមានចម្ងាយពីគ្នាចន្លោះ ១៥នាទី ក្នុងធ្វើដំណើរពីទីតាំងមួយទៅទីតាំងមួយទៀត។ ទីសត្តឃាតទាំងអស់នេះប្រើរណ្តៅទឹកដើម្បីសម្លាប់សត្វឆ្កែ។

១.៤ ផលកម្រៃ

ខាងក្រោមនេះជាតម្លៃនៃសត្វឆ្កែរស់ និងសាច់ឆ្កែ ៖

- សត្វឆ្កែរស់ ៨,០០០រ-១២,២០០រ ($2.00-$3.00) ក្នុងមួយគីឡូ
- សាច់ឆ្កែឆៅ ១១,០០០រ-១៧,០០០រ ($2.75-$4.25) ក្នុងមួយគីឡូ
- សម្លសាច់ឆ្កែ (សម្លរម្ងូរ ឬការី) នៅតាមភោជនីដ្ឋាន: ៥,០០០រ ($1.25)
- សាច់អាំង: ៥០,០០០រ ($12.50) ក្នុងមួយគីឡូ

២. អតិថិជន

អតិថិជនបរិភោគសាច់ឆ្កែនៅក្នុងខេត្តសៀមរាប ក៏ដូចជានៅក្នុងប្រទេសកម្ពុជា ភាគច្រើនជាជនជាតិខ្មែរ និងវៀតណាម និងមានភ្ញៀវទេសចរណ៍ជនជាតិកូរ៉េ និងចិនមួយចំនួនតូច។ យោងតាមការស្រាវជ្រាវទីផ្សារដែលធ្វើឡើងដោយអង្គការ FOUR PAWS និង ARC អតិថិជនបរិភោគសាច់ឆ្កែភាគច្រើនជាបុរស មានអាយុជាមធ្យមពី ១៨-២៩ឆ្នាំ មានប្រាក់ចំណូលមធ្យម ២00-៣00ដុល្លារ និងភាគច្រើនជាកម្មករ។

៣. កេរ្តិ៍ឈ្មោះជាអន្តរជាតិ និងវិស័យទេសចរណ៍

សហគមន៍សាធារណៈ និងអ្នកនយោបាយជាច្រើននៅលើសកលលោកកាន់តែមាននិន្នាការមិនអាចអត់ឱនចំពោះអាជីវកម្មសាច់ឆ្កែ ខណៈដែលសម្លេងប្រឆាំងនឹងអាជីវកម្មនេះមានការកើនឡើងនៅក្នុងតំបន់ និងជុំវិញពិភពលោក។ សត្វឆ្កែត្រូវបានចាត់ទុកជាដៃគូ និងជាអ្នកការពារ មិនមែនជាសត្វសម្រាប់ធ្វើជាអាហារនោះទេ។ លើពិភពលោកនេះ មិនមានទីណាដែលអាចមើលឃើញច្បាស់ជាងប្រទេសកម្ពុជានោះទេ ដែលសត្វឆ្កែបានដើរតួនាទីយ៉ាងសំខាន់លើផ្នែកសន្តិសុខជាតិ ថែរក្សាសន្តិភាព និងធ្វើសកម្មភាពដោះមីន។ ចាប់តាំងពីចុងឆ្នាំ២០១៨ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន បានចេញរបាយការណ៍ ចាប់ពីខែមករា ឆ្នាំ២000 ដល់ខែសីហា ឆ្នាំ២០១៨ ស្តីពីចំនួនជនរងគ្រោះដែលបានស្លាប់ដោយសារគ្រោះថ្នាក់មីន ១.៤៤៤នាក់ និងរងរបួសចំនួន ៦.១៩២នាក់។ ក្នុងពេលបច្ចុប្បន្ននេះ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) មាន សុនខចំនួន ១.៣២ក្បាល ដែលក្នុងនោះសុនខចំនួន ៧0ក្បាល បានជួយនៅក្នុងប្រតិបត្តិការដោះមីន។ សុនខដែលប្រកបដោយវីរភាពទាំងនេះកំពុងអនុវត្តការងារជារៀងរាល់ថ្ងៃក្នុងប្រទេសកម្ពុជា ក្នុងការការពារជីវិត និងរួមចំណែកយ៉ាងធំធេងនៅក្នុងសង្គម។

រដ្ឋាភិបាលនៃប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ កំពុងចាត់វិធានការកាន់តែខ្លាំងដើម្បីដោះស្រាយបញ្ហាអាជីវកម្មសាច់ឆ្កែ។ ក្នុងខែកញ្ញា ឆ្នាំ២០១៨ អភិបាលរងរាជធានីហាណូយ ប្រកាសការហាមឃាត់អាជីវកម្មសាច់ឆ្កែត្រឹមឆ្នាំ២០២១ ដែលអាជីវកម្មនេះបានជះឥទ្ធិពលមិនល្អដល់កេរ្តិ៍ឈ្មោះជាអន្តរជាតិនៃរាជធានីហាណូយ។ ក្នុងខែសីហា ឆ្នាំ២០១៨ រដ្ឋមន្ត្រីក្រសួងកសិកម្មឥណ្ឌូនេស៊ី បានប្រកាសពីការគាំទ្រការហាមឃាត់អាជីវកម្មសាច់ឆ្កែ និងសាច់ឆ្មា។

> **មានមនុស្សតិចណាស់ដែលបានដឹងថានៅចម្ងាយត្រឹមតែ ២-៣គីឡូម៉ែត្រពីទីតាំងអច្ឆរិយដ៏មហស្ចារ្យ គឺជាកន្លែងដែលសត្វឆ្កែរាប់ពាន់ក្បាលត្រូវបានគេសម្លាប់យ៉ាងឃោរឃៅជារៀងរាល់ថ្ងៃ**

ជារៀងរាល់ឆ្នាំភ្ញៀវទេសចរណ៍ច្រើនជាង ១លាននាក់ ជុំវិញពិភពលោក មកទស្សនាប្រាសាទអង្គរវត្ត។ មានមនុស្សតិចណាស់ដែលបានដឹងថានៅចម្ងាយត្រឹមតែ ២-៣ គីឡូម៉ែត្រ ពីទីតាំងអច្ឆរិយដ៏មហស្ចារ្យ គឺជាទីកន្លែងដែលសត្វឆ្កែរាប់ពាន់ក្បាលត្រូវបានគេសម្លាប់យ៉ាងឃោរឃៅជារៀងរាល់ថ្ងៃ។ ជាការពិតភ្ញៀវទេសចរណ៍អន្តរជាតិជាច្រើនបានឆ្លងកាត់តំបន់ស្តុកសាច់ឆ្កែដ៏ធំដោយមិនដឹងខ្លួននៅតាមផ្លូវទៅកាន់ ប្រាសាទបន្ទាយសំរែ រៀងរាល់សប្តាហ៍។ ដោយសារភាពងាយស្រួលក្នុងការមើលឃើញយ៉ាងច្បាស់នូវភោជនីយដ្ឋានលក់សាច់ឆ្កែ ភ្ញៀវទេសចរណ៍មួយចំនួនបានចាប់ផ្តើមគ្មួញឆ្អែរ

អំពីអាជីវកម្មសាច់ឆ្កែ។ ម្ចាស់ភោជនីយដ្ឋានលក់សាច់ឆ្កែមួយកន្លែងដែលមានទីតាំងនៅក្បែរនឹងប្រាសាទអង្គរវត្ត បានដឹងអំពីការមិនសប្បាយចិត្តរបស់ភ្ញៀវទេសចរណ៍មកពីប្រទេសលោកខាងលិច គាត់បានបង្កើនការប្រុងប្រយ័ត្នចំពោះការផ្សព្វផ្សាយអាជីវកម្មរបស់គាត់។

ខេត្តសៀមរាប បានក្លាយជាប្រធានបទជាអន្តរជាតិ ក្នុងពេលថ្មីៗនេះ ស្តីពីការប្រកាសហាមឃាត់ការជិះសត្វដំរី។ សកម្មភាពប្រឆាំងនឹងអាជីវកម្មសត្វឆ្កែគួរតែត្រូវបានប្រារព្ធធ្វើដូចគ្នានៅទូទាំងពិភពលោក។

៤. ជម្ងឺឆ្កែឆ្កួត និងហានិភ័យចំពោះសុខភាពសាធារណៈផ្សេងទៀត

ជម្ងឺឆ្កែឆ្កួត គឺជាជម្ងឺឆ្លងដែលបង្កឡើងមកពីវីរុសមានប្រភពមកពីហ្សែន Lyssavirus ធ្វើឱ្យប៉ះពាល់ដល់ ប្រព័ន្ធសរសៃប្រសាទកណ្តាលនៃពពួកសត្វដែលមានឈាមក្តៅ ដោយរួមបញ្ចូលទាំងមនុស្សផងដែរ។ ជាធម្មតាការចម្លងជម្ងឺឆ្កែឆ្កួតកើតឡើងតាមរយៈការខាំ ឬក្រញៅ (ជាទូទៅតាមរយៈទឹកមាត់ ពីសត្វដែលមានផ្ទុកមេរោគនេះ។ មានករណីរហូតដល់ ៩៩% កើតឡើង ដោយសត្វឆ្កែចិញ្ចឹមជាសត្វដែលចម្លងជម្ងឺឆ្កែឆ្កួតទៅមនុស្ស។ ជម្ងឺឆ្កែឆ្កួត ១០០% គឺជាជម្ងឺដែលអាចបណ្តាលឱ្យស្លាប់ ប៉ុន្តែវាជាជម្ងឺដែលអាចបង្ការបាន ១០០% ប្រសិនបើត្រូវបានព្យាបាលទាន់ពេល គឺនៅមុនពេលចាប់ផ្តើមលេច ចេញរោគសញ្ញា។ នៅក្នុងប្រទេសកម្ពុជា មានការប៉ាន់ប្រមាណថាមានមនុស្សស្លាប់ ៨០០នាក់ ដោយសារជម្ងឺឆ្កែឆ្កួតជារៀងរាល់ឆ្នាំ ប៉ុន្តែចំនួនករណីស្លាប់ពិតប្រាកដអាចមានច្រើនជាងនេះ។ កម្ពុជាជាប្រទេស ដែលអត្រាជំងឺឆ្កែឆ្កួតលើមនុស្សខ្ពស់ជាងគេលើពិភពលោក។

អាជីវកម្មសាច់ឆ្កែ គឺមិនស្របទៅនឹងការលុបបំបាត់ជម្ងឺឆ្កែឆ្កួត ដោយវាធ្វើឱ្យអ្នកទាក់ឆ្កែ អ្នកដឹកជញ្ជូន អ្នកសម្លាប់ អ្នកបរិភោគ និងសាធារណៈជន ប្រឈមនឹងហានិភ័យក្នុងការឆ្លងជម្ងឺនេះ។ ប្រភពសត្វឆ្កែ និងការដឹកជញ្ជូនសត្វឆ្កែពីបណ្តាខេត្តដែលមានអត្រារាលដាលនៃជម្ងឺឆ្កែឆ្កួតខ្ពស់ទៅកាន់ភោជនីយដ្ឋាន និងទីសត្តឃាតទូទាំងប្រទេស និងអន្តរជាតិ គឺផ្ទុយទៅនឹងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងលុបបំបាត់ជម្ងឺឆ្កែឆ្កួតដោយស្ថាប័នទីប្រឹក្សាសុខភាព រួមមានអង្គការសុខភាពពិភពលោក អង្គការ PAN American Health Organisation (PHAO) និងអង្គការស្បៀង និងកសិកម្មរបស់អង្គការសហប្រជាជាតិ (FAO)។

ការកើនឡើងនៃការទទួលស្គាល់ និងភស្តុតាងនៃហានិភ័យនៅគ្រប់ដំណាក់កាលក្នុងអាជីវកម្មសាច់ឆ្កែដែលបង្កឱ្យមានការឆ្លងជម្ងឺឆ្កែឆ្កួតទៅមនុស្ស ដូចនេះរាល់ការព្យាយាមណាមួយក្នុងការលុបបំបាត់ជម្ងឺឆ្កែឆ្កួតនៅក្នុងខេត្តសៀមរាប និងបណ្តាខេត្តផ្សេងទៀតនឹងជួបភាពបរាជ័យប្រសិនបើមិនមានដំណោះស្រាយចំពោះអាជីវកម្មសាច់ឆ្កែសម្រាប់មនុស្សបរិភោគ។ មជ្ឈមណ្ឌលត្រួតពិនិត្យ និង បង្ការជម្ងឺ សហរដ្ឋអាមេរិក (US CDC) បានប្រកាសថា ៖

> *“មានរបាយការណ៍បញ្ជាក់ថាទីផ្សារលក់សាច់ឆ្កែមានអត្រាជម្ងឺឆ្កែឆ្កួតខ្ពស់ជាងចំនួនសត្វឆ្កែទូទៅ ពីព្រោះប្រជាជនជារឿយៗលក់សត្វឆ្កែរបស់ពួកគេទៅកាន់ទីផ្សារនៅពេលពួកវាបង្ហាញអាការៈឈឺ ហើយសត្វឆ្កែមួយចំនួនដែលមានជម្ងឺឆ្កែឆ្កួត។ លើសពីនេះទៅទៀត យ៉ាងហោចណាស់មានរបាយការណ៍ចំនួន ០៣ ដែលបានចោះពុម្ពផ្សាយអំពីមនុស្សដែលឆ្លងជម្ងឺឆ្កែឆ្កួតតាមរយៈសកម្មភាពដែលពាក់ព័ន្ធជាមួយទីផ្សារសាច់ឆ្កែ ដោយបានបង្ហាញថាហានិភ័យពិតជាមានខ្ពស់។”*
>
> – CDC, ខែកុម្ភៈ ២០១៨

ចាប់តាំងពីឆ្នាំ២០០០ វិទ្យាស្ថានប៉ាស្ទ័រនៅកម្ពុជា បានធ្វើការវិភាគជាមធ្យមករណីឆ្កែខាំចំនួន ២០០ករណី ជារៀងរាល់ឆ្នាំ។ លទ្ធផលជិត ៥០% នៃការវិភាគបានបង្ហាញថាបានឆ្លងជម្ងឺឆ្កែឆ្កួតដែលអាចបង្កឱ្យស្លាប់បាន។ នៅក្នុងកំឡុងការអង្កេត សត្វឆ្កែដែលកំពុងឈឺ និងមានជម្ងឺ ត្រូវបានសម្លាប់ជាប្រចាំដើម្បីយកសាច់លក់ ក៏ដូចជាសត្វដែលត្រូវបានសម្លាប់តាមរបៀបមួយដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សាធារណៈនិងអ្នកបរិភោគ។ តាមរយៈការចោះពុម្ពផ្សាយពីការស្រាវជ្រាវកន្លងមកបានបង្ហាញ ភស្តុតាងនៃការឆ្លងជម្ងឺឆ្កែឆ្កួតទៅមនុស្សនៅតាមដំណាក់កាលនីមួយៗនៃខ្សែសង្វាក់ផ្គត់ផ្គង់សាច់ឆ្កែ គឺអ្នកសម្លាប់ឆ្កែ អ្នកកាប់សាច់ អ្នករៀបចំ និងអ្នកបរិភោគសាច់ឆៅ។ ម្យ៉ាងវិញទៀត អ្នកទាក់ឆ្កែ និងអ្នកដែលពាក់ព័ន្ធទៅនឹងអាជីវកម្មបានប្រឈមហានិភ័យ

ឆ្កែខាំ និងដាច់រលាត់ផងដែរ ដោយសារតែស្ថានភាពស្ត្រេសជុំវិញការចាប់ឆ្កែ ហើយឆ្កែជាច្រើនមិនធ្លាប់ត្រូវបានចាប់។ អ្នកធ្វើអាជីវកម្មសាច់ឆ្កែជាច្រើនបានរាយការណ៍អំពីការខាំកាលពីកន្លងមក។

ការអង្កេតបានរកឃើញថា ៖

- សត្វឆ្កែដែលស្ថិតក្នុងការសង្ស័យកម្រិតខ្ពស់ថាមានជម្ងឺឆ្កែឆ្កួត (មានបញ្ហាប្រសាទ ឬត្រូវបានខាំ) ជារឿយៗត្រូវបានគេលក់ដើម្បីយកសាច់ ពីព្រោះសត្វឆ្កែទាំងនោះមានជម្ងឺ ឬផ្លាស់ប្តូរឥរិយាបថ។
- នៅតាមបណ្តាទីសត្តឃាត និងភោជនីយដ្ឋាន សត្វឆ្កែត្រូវបានគេវាយធ្វើបាបជាប្រចាំទៅលើក្បាលបណ្តាលឱ្យមានការហូរឈាមនៅខាងក្នុង និងបង្កឱ្យមានបញ្ហាខួរក្បាល។
- សត្វឆ្កែដែលបង្ហាញអាការៈថាមានជម្ងឺ រួមទាំងបញ្ហាប្រសាទដែលជាសញ្ញាសង្ស័យក្នុងការឆ្លងជម្ងឺឆ្កែឆ្កួតត្រូវបានសម្លាប់ដើម្បីយកសាច់។
- អ្នកប្រកបអាជីវកម្ម និងកាប់សាច់មិនបានប្រើប្រាស់ឧបករណ៍ចាំបាច់ដើម្បីការពារខ្លួនរបស់ពួកគេពីការខាំ ឬមុតរបួសនោះឡើយ។
- មានរបាយការណ៍អំពីសត្វឆ្កែដែលត្រូវបានគេបំពុល ហើយសពរបស់ឆ្កែត្រូវបានគេយកទៅបរិភោគ។
- ជួនកាលខួរក្បាលរបស់សត្វឆ្កែត្រូវបានគេយកមកបរិភោគជាអាហារពេលល្ងាចនៅតាមភោជនីយដ្ឋាន។

មានរបាយការណ៍តាមរយៈសារព័ត៌មានអេឡិចត្រូនិច (Online បង្ហាញការផ្សារភ្ជាប់រវាងអ្នកបរិភោគសាច់ឆ្កែ និងជម្ងឺឆ្កែឆ្កួតនៅកម្ពុជា ៖

- Cambodia deaths linked to barbequed dog carcasses (2015) CBS News
- Doctors confirm that consuming rabid dog or cat meat is a risk for health (2019) Mekong Post News

៥. សំណើកិច្ចសហការ និងយុទ្ធសាស្ត្រដោះស្រាយជាមូលដ្ឋាន

FOUR PAWS និង ARC មានគម្រោងលើកសំណើយុទ្ធសាស្ត្រនៃកិច្ចសហការដើម្បីគាំទ្រដល់អាជ្ញាធរខេត្តសៀមរាប ក្នុងការដោះស្រាយអាជីវកម្មសាច់ឆ្កែ ដោយផ្អែកទៅលើ ៖

- ក្តីបារម្ភពីសុខមាលភាពរបស់សត្វ ៖ មានឯកសារជាភស្តុតាងដែលបានបង្ហាញពីភាពសាហាវឃោរឃៅចំពោះសត្វនៅគ្រប់ដំណាក់កាលនៃអាជីវកម្មសាច់ឆ្កែក្នុងខេត្តសៀមរាប និងតំបន់ផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីការចាប់ ការដឹកជញ្ជូន ការលក់ដើម្បីកាប់សាច់។
- ក្តីបារម្ភពីសុខភាពសាធារណៈ ៖ សត្វឆ្កែដែលមានជម្ងឺត្រូវបានដាក់បញ្ចូលទៅក្នុងខ្សែសង្វាក់អាហារ ទីសត្តឃាតសាច់ឆ្កែទាំងអស់គ្មានអនាម័យ ប្រតិបត្តិការខុសច្បាប់ និងលក់ផលិតផលអាហារដែលគ្មានសុវត្ថិភាព។ ក៏ជាក្តីបារម្ភផងខ្លាំងផងដែរចំពោះសត្វឆ្កែដែលមានជម្ងឺឆ្កែឆ្លងតត្រូវបានលក់យកសាច់ ធ្វើឱ្យប៉ះពាល់សុខភាពដល់អ្នកកាប់សាច់ អ្នកបរិភោគ និងអ្នកធ្វើអាជីវកម្ម។ មានភស្តុតាងផ្សារភ្ជាប់ការធ្វើអាជីវកម្មសាច់ឆ្កែទៅនឹងការកើនឡើងជម្ងឺឆ្កែឆ្លងតនៅតាមប្រទេសជាច្រើន។ ពិចារណាទៅលើគោលដៅរបស់ប្រទេសកម្ពុជា និងអាស៊ានក្នុងការលុបបំបាត់ជម្ងឺឆ្កែឆ្លងត ការមិនអាចគ្រប់គ្រងអាជីវកម្មទៅលើសត្វឆ្កែដែលមិនមានចាក់វ៉ាក់សាំង និងការបម្លាស់ទីជាប្រចាំទៅកាន់ ឬចេញពី ខេត្តសៀមរាប និងតំបន់ផ្សេងទៀតក្នុងប្រទេសកម្ពុជា នឹងមិនធ្វើឱ្យការសម្រេចគោលដៅនេះទទួលបានជោគជ័យនោះទេ។
- ភាពខុសច្បាប់ ៖ ទីសត្តឃាតសត្វឆ្កែទាំងអស់មិនមានអាជ្ញាបណ្ណ និងមិនអាចបំពេញបានស្តង់ដារអនាម័យជាមូលដ្ឋាន។ អនុក្រឹត្យលេខ ១០៨ អនក្រ.បក ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសាច់ សត្វ និងផលិតផលសត្វ ត្រូវធ្វើឡើងដើម្បីការពារការរីករាលដាលនៃជម្ងឺរបស់សត្វ ការពារសុខភាពរបស់សត្វ ធានាបានគុណភាពផលិតផល និងការពារសុខភាពសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មាត្រា ៩ បានចែងថា *"ការលក់សាច់ និងផលិតផលសត្វដែលមានប្រភពមេរោគបង្កជម្ងឺឆ្លងរាតត្បាត ឬមានមេរោគបង្កជម្ងឺឆ្លងរាតត្បាតដល់សត្វ ឬមនុស្ស ត្រូវហាមឃាត់ និងទទួលការផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។"* ប៉ុន្តែដោយសារសត្វឆ្កែមិនត្រូវបានរាប់បញ្ចូលនៅក្នុងអនុក្រឹត្យលេខ ១០៨ អនក្រ.បក ដូចច្នេះទីសត្តឃាតសាច់ឆ្កែមិនអាចចុះបញ្ជីស្របច្បាប់បានឡើយ។

ម្យ៉ាងវិញទៀត អាជីវកម្មសាច់ឆ្កែក៏បានផ្ទុយទៅនឹងជំពូកទី ៨ (ទីសត្តឃាត និងអនាម័យ ជំពូកទី ៩ (ការបម្លាស់ទីសត្វ និងផលិតផលសត្វ ជំពូកទី ១១ (សុខមាលភាពសត្វ និងជំពូកទី ១៩ (អធិការកិច្ច នៃច្បាប់ស្តីពីសុខភាពសត្វ និង ផលិតកម្មសត្វ ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិនាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។

- ការខូចខាតជាសក្តានុពលដល់វិស័យទេសចរណ៍អន្តរជាតិ និងកេរ្តិ៍ឈ្មោះ ៖ ខណៈពេលដែលចំនួនប្រទេសកាន់តែច្រើនជុំវិញពិភពលោកកំពុងធ្វើសកម្មភាពដើម្បីដោះស្រាយអាជីវកម្មសាច់ឆ្កែ សហគមន៍សាធារណៈ និងអ្នកនយោបាយនៅលើសកលលោក កាន់តែមិនអត់ឱនចំពោះអាជីវកម្មសាច់ឆ្កែ ការកើនឡើងសម្លេងប្រឆាំងនៅក្នុងតំបន់ ក្នុងប្រទេសកម្ពុជា និងជុំវិញពិភពលោក។
- មានឆន្ទៈរួចជាស្រេចនៅក្នុងតំបន់ដើម្បីដោះស្រាយអាជីវកម្មសាច់សត្វ ៖ ការមានសត្វចិញ្ចឹមកាន់តែទទួលបានការពេញនិយម ប្រជាជនខ្មែរជាច្រើនកំពុងក្រោកប្រឆាំងនឹងអាជីវកម្មសាច់ឆ្កែ។ ជ្រើសរើសស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាដែលកំពុងគាំទ្រដល់ការបញ្ចប់អាជីវកម្មសាច់ឆ្កែ។ ក្នុងខែកក្កដា ឆ្នាំ២០១៩ CMAC អង្គការ FOUR PAWS និងអង្គការ ARC បានរៀបចំសិក្ខាសាលានៅក្នុងរាជធានីភ្នំពេញដើម្បីអបអរអំពីតួនាទីដ៏សំខាន់របស់សត្វឆ្កែនៅក្នុងសង្គមខ្មែរ និងពិភាក្សាការគម្រាមកំហែងដល់សុខមាលភាពសត្វ ដែលបង្កឡើងដោយអាជីវកម្មសាច់ឆ្កែ។ សិក្ខាសាលានេះមានការចូលរួមពីសំណាក់មន្ត្រីរាជរដ្ឋាភិបាលដែលពាក់ព័ន្ធចំនួន ៧០នាក់ ដែលរួមមានអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងនាយកដ្ឋានប្រឆាំងភេរវកម្ម និងប្រឆាំងគ្រឿងញៀន។

- វប្បធម៌ និងសាសនា ៖ សាច់ឆ្កែមិនត្រូវបានបង្ហាញថាជាអាហារប្រពៃណី និងការពិត បានបង្ហាញ តាមរយៈ អ្នកបរិភោគសាច់ឆ្កែ ដែលបានអះអាងថាមិនមែនជាផ្នែកមួយនៃវប្បធម៌របស់ប្រទេសកម្ពុជានោះទេ។ ម្យ៉ាងវិញ ទៀតសាច់ឆ្កែត្រូវបានដកស្រង់ថាជាសាច់មួយក្នុងចំណោមអាហារទាំង ១០ ដែលហាម ឃាត់ក្នុង គម្ពីរ ព្រះពុទ្ធសាសនា។

៦. អនុសាសន៍

អង្គការ FOUR PAWS និងអង្គការ ARC មានគោលបំណងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងអាជីវកម្មសាច់ឆ្កែដោយផ្អែកលើសុខភាពសាធារណៈ សុខមាលភាពសត្វ និងវិស័យទេសចរណ៍។ ខាងក្រោមនេះជាអនុសាសន៍សកម្មភាពនៃកិច្ចសហការ ដោយផ្អែកលើការស៊ើបអង្កេត និងការសិក្សាស្រាវជ្រាវទីផ្សារ ៖

១. ចងក្រងផែនការសហគមន៍ដើម្បីបិទបញ្ចប់សកម្មភាពពាក់ព័ន្ធអាជីវកម្មសាច់ឆ្កែ។

២. ចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយក្នុងតំបន់ និងថ្នាក់ជាតិ ដើម្បីប្រកាសថាអាជីវកម្មសាច់ឆ្កែនឹងមិនត្រូវបានអត់ឱនដោយផ្អែកលើការបង្កអន្តរាយដល់វិស័យទេសចរណ៍ សុខភាពសាធារណៈ និងសុខមាលភាពសត្វ។ ការពង្រឹងការអនុវត្តច្បាប់ និងជួយសង្គ្រោះសត្វឆ្កែ ជាមួយការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធិភាព ដែលជាការបញ្ជូនសារដ៏ខ្លាំងមួយទៅកាន់ឧស្សាហកម្មនេះ ថារាល់ផលិតកម្ម និងការលក់សាច់សត្វមិនទទួលបានការអត់ឱនទៀតទេ។

៣. អភិវឌ្ឍ និងអនុវត្តកម្មវិធីផ្តល់ចំណេះដឹង និងការអប់រំឱ្យបានទូលំទូលាយតាមរយៈការជួយរបស់ប្រព័ន្ធផ្សព្វផ្សាយថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីបង្កើនចំណេះដឹងអំពីហានិភ័យនៃអាជីវកម្មសាច់ឆ្កែ ជាពិសេសចំពោះជម្ងឺឆ្កែឆ្លងត។

៤. ចេញសេចក្តីប្រកាសព័ត៌មានជាអន្តរជាតិដើម្បីអបអរដល់សកម្មភាពរបស់អាជ្ញាធរខេត្តសៀមរាប ក្នុងការប្រយុទ្ធប្រឆាំងអាជីវកម្មសាច់ឆ្កែ ដើម្បីលើកកម្ពស់មុខមាត់ជាគោលដៅទេសចរណ៍កម្រិតពិភពលោក។

៥. ពិចារណាគោលដៅទៅលើការគ្រៀវសត្វឆ្កែ និងចាក់វ៉ាក់សាំងការពារជម្ងឺឆ្កែឆ្លងនៅតាមកន្លែងដែលមានសត្វឆ្កែ និងឆ្កែដែលមានម្ចាស់ ដើម្បីកាត់បន្ថយកំណើននៃកូនឆ្កែដែលមិនចង់បានជារៀងរាល់ឆ្នាំ និងលុបបំបាត់ជម្ងឺឆ្កែឆ្លង។

អង្គការ FOUR PAWS និងអង្គការ ARC បានត្រៀមខ្លួនរួចជាស្រេចដើម្បីជួយដល់រាជរដ្ឋា-ភិបាលតាមរយៈយុទ្ធនាការទូលំទូលាយប្រកបដោយប្រសិទ្ធភាព និងភាពជាវិជ្ជមានដើម្បីដោះស្រាយទៅនឹងសកម្មភាពដែលពាក់ព័ន្ធជាមួយអាជីវកម្មសាច់ឆ្កែ ដោយផ្អែកលើបទពិសោធន៍ជាច្រើនឆ្នាំលើការងារនេះនៅក្នុងប្រទេសកម្ពុជា និងសកលលោកលើបញ្ហាសុខមាលភាពសត្វ រួមបញ្ចូលអាជីវកម្មសាច់ឆ្កែ ការរឹបអូសសត្វរស់ ការសង្គ្រោះ ការស្តារនីតិសម្បទា។ អង្គការទាំងពីរអាចផ្តល់ដល់អាជ្ញាធរនូវអ្នកជំនាញការ ការគាំទ្រ និងធនធានដែលចាំបាច់ដើម្បីធានាបាននូវយុទ្ធសាស្ត្ររួម ដោយកំណត់គោលដៅលើសកម្មភាពខុសច្បាប់ និងផ្តល់ការអប់រំជាសាធារណៈអំពីគ្រោះថ្នាក់នៃអាជីវកម្មសាច់ឆ្កែ។

VIER PFOTEN International

Linke Wienzeile 236
1150 Vienna, Austria
phone: +43-1-545 50 20-0
office@four-paws.org

four-paws.org
facebook.com/fourpaws.org
twitter.com/fourpawsint
youtube.com/fourpawsinternational
instagram.com/four_paws_international

Animal Rescue Cambodia

#269, St. 41 BT
Boeung Tumpun, Cambodia
phone: +855 (0)12 340 114
info@ar-cambodia.com

ar-cambodia.com
facebook.com/animalrescuecambodia
twitter.com/ARCambodia
youtube.com/animalrescuecambodia
instagram.com/animal.rescue.cambodia

photos: © FOUR PAWS, Angkor Wat © boule13; artwork: Virtuality 09/2019